multi cultural communication

ផលិតចងក្រងដោយ NSW HEALTH DEPARTMENT

Khmer-ខ្មែរ

July 1998
[DOH-6345]

# ការឆែកពិនិត្យសុខភាពទារកទើបកើត: ការធ្វើតេស្តពិនិត្យមើលដើម្បីការពារកូនអ្នក
# Newborn Screening: Tests to protect your baby

អត្ថបទខាងក្រោមនេះផលិតចងក្រងឡើងដោយក្រសួងសុខាភិបាលរដ្ឋញូវសោវវែលស៍។

*សូមរក្សាទុកពត៌មាននេះរហូតទាល់តែកូនអ្នកមានអាយុ៣ខែ ក្រែងលោលោកអ្នកត្រូវការមើលពត៌មាននេះម្តងទៀត។*

**ការពិនិត្យតាមដានរកបញ្ហាដែលកម្រកើតមាន**

ទារកទើបកើតត្រូវឆ្លងកាត់ការធ្វើតេស្តពិនិត្យសុខភាពដ៏សំខាន់នេះ មុននឹងចេញទៅផ្ទះពីមន្ទីរពេទ្យ ក្រោយពេលប្រសូត្ររួចបានរវាងពី៤៨ ទៅ៧២ម៉ោង។  ការធ្វើតេស្តនេះ គឺជាផ្នែកមួយនៃការពិនិត្យថែទាំសុខភាពជាប្រចាំសំរាប់កូនអ្នក។

បញ្ហាដ៏កម្រជាង៣០ប្រភេទ ឥឡូវនេះអាចត្រូវគេតាមដានរកឃើញ ដោយការធ្វើតេស្តឆែកពិនិត្យទារកទើបកើត។ បុគ្គលិកនឹងធ្វើការពិភាក្សាអំពីរឿងធ្វើតេស្តនេះ ជាមួយលោកអ្នក ហើយពន្យល់ប្រាប់អំពីមូលហេតុដែលបង្ហាញថា ការឆែកពិនិត្យសុខភាពនេះ មានសារសំខាន់ដល់សុខភាពកូនលោកអ្នក។ បុគ្គលិកត្រូវតែសុំការយល់ព្រមជាពាក្យពេចន៍ ពីលោកអ្នកជាមុនសិន ដើម្បីឲ្យគេអាចធ្វើតេស្តនេះបាន។

ទារកប្រមាណជា៩០នាក់ ដែលមានបញ្ហាសុខភាពដ៏កម្រ បានត្រូវគេរកឃើញជារៀងរាល់ឆ្នាំតាមរយៈការធ្វើតេស្តឆែកពិនិត្យសុខភាពនេះ។

បើសិនជាគេរកឃើញថាកូនលោកអ្នកមានបញ្ហាអ្វីមួយនោះ ការព្យាបាលអាចចាប់ផ្តើមបានយ៉ាងឆាប់មិនឲ្យកូនលោកអ្នកឈឺទាន់ឡើយ។

ចំពោះការធ្វើតេស្តវិញ គេគ្រាន់តែយកឈាម២-៣ដំណក់ពីកែងជើងកូនលោកអ្នក ដោយប្រើក្រដាសពិសេសផ្តិតយកឈាមនោះ។ សំណាកឈាមស្ងួតនោះ នឹងត្រូវគេបញ្ជូនទៅមន្ទីរពិសោធន៍ឆែកពិនិត្យសុខភាពទារកទើបកើត រដ្ឋញូវសោវវែលស៍ ឋិតនៅឯមន្ទីរពេទ្យកុមារនៅ វេស្តមីដ (Westmead)។

**សូមមេត្តាធ្វើឲ្យប្រាកដថា កូនលោកអ្នកធ្វើតេស្តឆែកពិនិត្យសុខភាពនេះ ហើយកត់ត្រាថ្ងៃខែឆ្នាំនៃការធ្វើតេស្តនេះ នៅក្នុងសៀវភៅកំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់កូនលោកអ្នក។**

## ពត៌មានអំពីបញ្ហាទាំងនេះ

### ការមានបញ្ហាក្រពេញថាយរ៉ូយ (**Hypothyroidism**) ពីកំណើត:

បញ្ហានេះកើតមានឡើងចំពោះទារកប្រមាណជា២៦នាក់ជារៀងរាល់ឆ្នាំ នៅក្នុងរដ្ឋញូវសាវ៉ែលស៍/ដែនដីរាជធានីអូស្រ្តាលី។ បញ្ហានេះកើតមានឡើងនៅពេលក្រពេញថាយរ៉ូយមានទំហំតូចហួស, គ្មានវត្តមាន ឬក៏មិនដំណើរការ។ ការព្យាបាលឆាប់ទាន់ពេលវេលា នាំឲ្យរាងកាយនិងខួរក្បាលកូនលូតលាស់ធម្មតា។ ការព្យាបាលគឺតម្រូវឲ្យមានការផ្តល់ថ្នាំអ័រម៉ូនថាយរ៉ូយមួយគ្រាប់តូចទៅកូនជារៀងរាល់ថ្ងៃ។

### បញ្ហាហ្វីណលកេតូនូរៀ ( **Phenylketonuria** ):

បញ្ហានេះកើតមានឡើង ចំពោះទារកប្រហែលជា១០នាក់ក្នុងមួយឆ្នាំៗ នៅក្នុងរដ្ឋញូវសាវ៉ែលស៍/ដែនដីរាជធានីអូស្រ្តាលី។ ទារកដែលមានបញ្ហានេះ មិនអាចប្រើសារជាតិ ហ្វីណលឡាឡានីន (phenylalanine) (ដែលអាចជួយបង្កើតប្រូតេអ៊ីននៅក្នុងខ្លួន)។ បើសិជាគ្មានការព្យាបាលទេនោះ ហ្វីណលឡាឡានីននេះកកើនឡើងនៅក្នុងឈាម ហើយនាំឲ្យខូចខួរក្បាល។ ការព្យាបាល គឺធ្វើឡើងដោយការប្រកាន់នូវរបបអាហារដែលមានសារជាតិហ្វីណលឡាឡានីន (ប្រតេអ៊ីន) ក៏រិតទាប ហើយកូនលោកអ្នកនឹងមានការលូតលាស់ជាធម្មតា។

### បញ្ហាហ្កាឡាកទូស៊ីមៀ (**Galactosaemia** ):

បញ្ហានេះកើតមានឡើងចំពោះទារកប្រហែលជាម្នាក់ទៅ៣នាក់ក្នុងមួយឆ្នាំៗ នៅក្នុងរដ្ឋញូវសាវ៉ែលស៍/ដែនដីរាជធានីអូស្រ្តាលី។ បញ្ហានេះបង្កឡើងដោយសារ ជាតិស្ករមួយប្រភេទ ក្នុងចំណោមជាតិស្ករ (ហ្កាឡាកតូស) មាននៅក្នុងទឹកដោះ (ទាំងទឹកដោះម្តាយនិងទឹកដោះគោ) កកើនឡើងនៅក្នុងឈាម។ បើសិនជាមានការព្យាបាលឲ្យបានត្រឹមត្រូវទាន់ពេល ដោយការប្រើទឹកដោះពិសេស ដែលគ្មានផ្ទុកជាតិហ្កាឡាកតូសនោះ គេអាចទប់ស្កាត់ជម្ងឺធ្ងន់ធ្ងរបាន។ ទារកដែលមានបញ្ហានេះ ហើយមិនបានទទួលការព្យាបាលអាចធ្លាក់ខ្លួនឈឺយ៉ាងធ្ងន់ហើយស្លាប់។

### ជម្ងឺស៊ីស្ទីក ហ្វាយប្រ៊ូស៊ីស ( **Cystic Fibrosis** ):

ជម្ងឺនេះកើតមានឡើងចំពោះទារកប្រហែលជា៣៨នាក់ក្នុងមួយឆ្នាំៗនៅក្នុងរដ្ឋញូវសាវ៉ែលស៍/ដែនដីរាជធានីអូស្រ្តាលី។ ជម្ងឺនេះបង្កឡើងដោយសាររាងកាយបង្កើតភ្នាសកោសិកាក្រាស់ជាងធម្មតានៅក្នុងពោះវៀននិងសួត។ បញ្ហានេះអាចបង្កើតឲ្យមានជម្ងឺសួត ឬក៏ការរាករូស ហើយអាចបញ្ឈប់មិនឲ្យទារកឡើងទម្ងន់។ ការរីកចំរើនផ្នែកវិទ្យាសាស្រ្តនិងវេជ្ជសាស្រ្តនាពេលថ្មីៗនេះ បានលើកស្ទួយនូវក្តីសង្ឃឹមសំរាប់ទារកដែលមានបញ្ហានេះ។

### បញ្ហាសុខភាពដទៃទៀត

បច្ចេកវិទ្យាថ្មីបានផ្តល់នូវលទ្ធភាពដើម្បីតាមដានរកបញ្ហាដ៏កម្របំផុតមួយចំនួន ដោយការប្រើសំណាកឈាមស្ងួត ដើម្បីឲ្យគេអាចចាប់ផ្តើមការព្យាបាលឲ្យបានឆាប់។ បញ្ហាសុខភាពដ៏កម្របំផុតទាំងនេះ ជារួម យាយីទារកប្រហែលជា១៥នាក់ក្នុងមួយឆ្នាំៗ ដោយរួមទាំងបញ្ហាអាស៊ីដខ្លាញ់ បញ្ហាអាស៊ីដអ័រហ្កានិក និងបញ្ហាអាស៊ីដអាមីណូ។ បញ្ហាទូទៅបំផុតក្នុងចំណោមបញ្ហាទាំងនេះ គឺ MCAD (medium-chain acyl CoA dehydrogenase-កង្វះសហអង់ហ្ស៊ីម)។ ការរកឃើញបញ្ហានេះនៅគ្រាដំបូង គឺមានសារសំខាន់ ដោយសារការដាក់របបលើចំណីអាហារ និងការប្រើថ្នាំពេទ្យអាចព្យាបាលបញ្ហាទាំងនេះបានភាគច្រើន។ បញ្ហានេះអាចបង្កឲ្យមានពិការភាព និងមរណភាព បើសិនជាគ្មានការគ្រប់គ្រងឲ្យសមស្របទេនោះ។


Website: http://mhcs.health.nsw.gov.au
e-mail: mhcs@sesahs.nsw.gov.au

ការធ្វើរោគវិនិច្ឆ័យគ្រាដំបូងនិងការព្យាបាលភ្លាមៗ មានសារសំខាន់ សំរាប់បញ្ហាទាំងអស់ដែលពិភាក្សានៅខាងលើនេះ៕

## លទ្ធផលនៃការធ្វើតេស្ត

មាតាបិតានឹងមិនទទួលនូវដំណឹងស្តីអំពីលទ្ធផលធម្មតានៃការធ្វើតេស្តពិនិត្យសុខភាពនេះឡើយ។

ទារកប្រហែលជាម្នាក់ក្នុងចំណោមទារក១០០នាក់នឹងត្រូវផ្តល់ឈាមឲ្យគេធ្វើតេស្តជាលើកទី២ បើសិនជាតេស្តលើកទី១មិនបានបុចលទ្ធផលច្បាស់លាស់។ មាតាបិតានឹងបានទទួលដំណឹងបើសិនជាគេត្រូវការធ្វើតេស្តជាលើកទី២នោះ។ ការធ្វើតេស្តលើកទី២ សឹងតែនឹងបុចលទ្ធផលធម្មតាជានិច្ច ហើយវេជ្ជបណ្ឌិតរបស់លោកអ្នកនឹងបានទទួលលទ្ធផលនេះ។

លទ្ធផលនៃការធ្វើតេស្តឈាម ដែលមានលក្ខណៈមិនធម្មតា គឺមានតែចំពោះទារកមួយចំនួនតូចប៉ុណ្ណោះ។ ការពិនិត្យតាមដានថែមទៀត គឺជារឿងចាំបាច់ ហើយអាចត្រូវការការព្យាបាល។ វេជ្ជបណ្ឌិតរបស់លោកអ្នកនឹងបានទទួលដំណឹងអំពីលទ្ធផលនេះ ហើយវេជ្ជបណ្ឌិតនឹងទាក់ទងលោកអ្នក។

ក្រោយពីសំណាកឈាមស្ងួតបានត្រូវគេធ្វើតេស្តពិនិត្យមើលហើយនោះ គេនឹងរក្សាទុកឈាមនោះនៅក្នុងមន្ទីរពិសោធន៍។  ជាការកម្រណាស់ ដែលគេនឹងប្រើឈាមនោះ នៅគ្រាក្រោយមកទៀត ដើម្បីផ្តល់ពត៌មានវេជ្ជសាស្ត្រថ្មី សំរាប់ផលប្រយោជន៍ដល់គ្រួសារ។ សំណាកឈាមដែលគេរក្សាទុកនោះ អាចត្រូវគេយកទៅប្រើដើម្បីការសិក្សាស្រាវជ្រាវ ក្រោយពីមានការបំបាត់ចោលនូវអត្តសញ្ញាណទាំងអស់ចេញហើយនោះ។ យ៉ាងណាមិញ ការធ្វើតេស្តថែមទៀតនៃសំណាកឈាមដែលមានអត្តសញ្ញាណសំគាល់កូនលោកអ្នក នឹងមិនប្រព្រឹត្តទៅដោយគ្មានការយល់ព្រមជាលាយល័ក្សអក្សរពីមាតាបិតាទាំងពីរ ឬអាណាព្យាបាលឡើយ។

ពត៌មាននេះ ថ្មីនិងបច្ចុប្បន្ននៅខែឧសភា ឆ្នាំ២០០៣។

កម្មវិធីឆែកពិនិត្យសុខភាពទារកទើបកើតរង្គញូវសោវវែលស៍ នៃមន្ទីរពេទ្យកុមារនៅឯវេស្តមីដ (Westmead ).
http://www.chw.edu.au/prof/services/newborn

បើសិនជាលោកអ្នកត្រូវការជំនួយដើម្បីប្រើទូរស័ព្ទជាភាសាអង់គ្លេស សូមទូរស័ព្ទទៅសេវាបកប្រែភាសា (TIS) លេខ 131 450 ។

លោកអ្នកអាចរកពត៌មានថែមទៀតជាភាសាលោកអ្នក នៅក្នុងអ៊ិនធឺណិតរបស់សេវាផ្តល់ពត៌មានពហុវប្បធម៌ (Multicultural Communication website):  http://mhcs.health.nsw.gov.au

លេខទូរស័ព្ទទាំងនេះ គឺជាលេខត្រឹមត្រូវ នៅគ្រាដែលបោះពុម្ពផ្សាយ ប៉ុន្តែមិនបានទទួលការកែតម្រូវជាប្រចាំទេ។ លោកអ្នកប្រហែលជាត្រូវតែឆែករកលេខទូរស័ព្ទទាំងនោះ នៅក្នុងសៀវភៅទូរស័ព្ទហើយ៕